**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ..៥៩០......សហវ.ប្រក

# ប្រកាស
# ស្តីពី
# ការកំណត់គោលការណ៍ យន្តការ នីតិវិធី និងការត្រួតពិនិត្យសម្រាប់ការប្រើប្រាស់ខ្ទាន់លើកទឹកចិត្តរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១១៣ អនក្រ.បក ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០២២ ស្តីពីការបង្កើតវិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ១៥៩ អនក្រ.បក ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២៣ ស្តីពីការកែសម្រួលមាត្រា៥០ មាត្រា៥១ មាត្រា៥២ និងមាត្រា៥៣ នៃអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៥ អនក្រ.បក ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២៣ ស្តីពីការបង្កើតនិងបំពេញបន្ថែមអគ្គនាយកដ្ឋានសេដ្ឋកិច្ចឌីជីថល ឱ្យស្ថិតនៅក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៥៤ អនក្រ.បក ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២៣ ស្តីពីការបង្កើតនិងបំពេញបន្ថែមអគ្គនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឱ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**ប្រការ១.-**

ប្រកាសនេះមានគោលដៅកំណត់គោលការណ៍ យន្តការ នីតិវិធី និងការត្រួតពិនិត្យសម្រាប់ការផ្តល់ការលើកទឹកចិត្ត ដល់ថ្នាក់ដឹកនាំ មន្ត្រីរាជការ បុគ្គលិក និងអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុប្រកបដោយសមធម៌ ស័ក្តិសិទ្ធិភាព ប្រសិទ្ធភាព សង្គតិភាព តម្លាភាព និងគណនេយ្យភាព ដោយប្រើប្រាស់ប្រាក់រង្វាន់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលត្រូវបានសម្រេចផ្តល់ជូនដោយរាជរដ្ឋាភិបាល។

**ប្រការ២.-**

ប្រកាសនេះមានគោលបំណងជាសារវន្តដូចខាងក្រោម៖

- ពង្រឹងនិងបង្កើនផលិតភាព គុណភាព ស័ក្តិសិទ្ធិភាព និងប្រសិទ្ធភាពនៃសមិទ្ធកម្មរបស់មន្ត្រីរាជការ ចំណុះអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ផ្តល់ការលើកទឹកចិត្តដល់ថ្នាក់ដឹកនាំ មន្ត្រីរាជការ បុគ្គលិក និងអង្គភាព ដោយផ្អែកលើសមិទ្ធកម្ម និង អនុលោមតាមគោលការណ៍គុណាធិបតេយ្យ ប្រកបដោយសមធម៌ សង្គតិភាព តម្លាភាព និងគណនេយ្យភាព
- ធានាសុខដុមនីយកម្មនៃគោលការណ៍ យន្តការ នីតិវិធី និងការត្រួតពិនិត្យនៃការផ្តល់ការលើកទឹកចិត្តដល់ ថ្នាក់ដឹកនាំ មន្ត្រីរាជការ បុគ្គលិក និងអង្គភាពដោយប្រើប្រាស់រង្វាន់នៅក្នុងក្របខណ្ឌនៃក្រសួងសេដ្ឋកិច្ចនិង ហិរញ្ញវត្ថុ
- រួមចំណែកទ្រទ្រង់ការអនុវត្តគោលនយោបាយរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រកបដោយស័ក្តិសិទ្ធិភាព និងប្រសិទ្ធភាព។

**ប្រការ៣.-**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះ ថ្នាក់ដឹកនាំ មន្ត្រីរាជការ បុគ្គលិកដែលបម្រើការងារក្រោមឱវាទ និង ក្រោមអាណាព្យាបាលក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងអង្គភាពក្រោមអាណាព្យាបាលរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

## ជំពូកទី២

## គោលការណ៍លើកទឹកចិត្ត

**ប្រការ៤.-**

ការលើកទឹកចិត្តគឺជាការផ្តល់ប្រាក់ឧបត្ថម្ភ ប្រាក់រង្វាន់ ឬមូលនិធិនានាបន្ថែមលើបៀវត្សរបស់ថ្នាក់ដឹកនាំ មន្ត្រីរាជការ និងបុគ្គលិកដែលបានបំពេញមុខងារនិងភារកិច្ចរបស់ខ្លួនប្រកបដោយផលិតភាព គុណភាព ស័ក្តិសិទ្ធិភាព ប្រសិទ្ធភាព និងគណនេយ្យភាព តាមការកំណត់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ប្រការ៥.-**

ការលើកទឹកចិត្ត ត្រូវផ្តល់ជូនចំពោះថ្នាក់ដឹកនាំ មន្ត្រីរាជការ បុគ្គលិក ឬអង្គភាព តាម ៤ ប្រភេទគឺ **ប្រាក់ឧបត្ថម្ភជីវភាព ប្រាក់ឧបត្ថម្ភមុខងារ ប្រាក់រង្វាន់សមិទ្ធកម្ម** និង **មូលនិធិគាំទ្រស្ថាប័ន**។ ការលើកទឹកចិត្ត នៃប្រភេទនីមួយៗត្រូវផ្តល់ តាមគោលការណ៍ដូចខាងក្រោម៖

- **ប្រាក់ឧបត្ថម្ភជីវភាព** ត្រូវផ្តល់ជូនមន្ត្រីរាជការ និងបុគ្គលិក/មន្ត្រីជាប់កិច្ចសន្យាទាំងឡាយណាដែលមានការ ទទួលស្គាល់ដោយប្រកាស សេចក្តីសម្រេច ឬមានការសម្រេចដោយឡែករបស់ប្រធានស្ថាប័នតាមរយៈការ វាយតម្លៃរបស់ **គ.ស.ល** ដែលមកបំពេញការងារទៀងទាត់តាមមុខងារប្រកបដោយគុណភាព និង ផលិតភាព។
- **ប្រាក់ឧបត្ថម្ភមុខងារ** ត្រូវផ្តល់ជូនថ្នាក់ដឹកនាំ មន្ត្រីរាជការ និងបុគ្គលិក ដែលបំពេញមុខងារពាក់ព័ន្ធនឹង ការងារដឹកនាំ ការងារសិក្សាស្រាវជ្រាវ ការងារអភិវឌ្ឍស្ថាប័ន និងការងារជំនាញចាំបាច់។



K

- **ប្រាក់រង្វាន់សមិទ្ធកម្ម** ត្រូវផ្តល់ជូនមន្ត្រីរាជការ បុគ្គលិក ឬអង្គភាព ដែលសម្រេចបានលទ្ធផលលើសគោលដៅកំណត់ ដូចជាការប្រមូលចំណូលបានលើសគោលដៅកំណត់ ការបង្កើតឱ្យមានផលចំណេញថវិកា ការសម្រេចលទ្ធផលការងារបានមុនផែនការកំណត់ ការសន្សំសំចៃថវិកាបានដោយចំណាយតិចជាងគោលការណ៍កំណត់។ល។
- **មូលនិធិគាំទ្រស្ថាប័ន** ត្រូវផ្តល់ជូនអង្គភាពដែលមានតម្រូវការចាំបាច់ មានផែនការអភិវឌ្ឍន៍ស្ថាប័នដែលរួមទាំងផែនការអភិវឌ្ឍន៍ធនធានមនុស្សប្រចាំឆ្នាំច្បាស់លាស់ និងដែលឆ្លើយតបពិតប្រាកដទៅនឹងសេចក្តីត្រូវការចាំបាច់នៃមុខងារក្នុងការអនុវត្តកម្មវិធី និងគោលនយោបាយរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងទៅតាមលទ្ធភាពជាក់ស្តែងនៃមូលនិធិរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ប្រការ៦.-**

ការលើកទឹកចិត្តត្រូវផ្តល់ទៅតាមសន្ទស្សន៍ តម្លៃឯកតានៃសន្ទស្សន៍ ភាគរយ និងលទ្ធភាពដែលត្រូវបានកំណត់នៅតាមតាមប្រភេទទាំង៤ ដូចខាងក្រោម៖

**ក-ប្រាក់ឧបត្ថម្ភជីវភាព** ត្រូវផ្តល់ប្រចាំខែ និងត្រូវបានកំណត់ជាសន្ទស្សន៍ ដូចខាងក្រោម៖

១-អគ្គលេខាធិការ/អគ្គនាយក/អគ្គាធិការ អគ្គលេខាធិការរង អគ្គនាយករង និង អគ្គាធិការរង និងមុខតំណែងប្រហាក់ប្រហែល មានសន្ទស្សន៍ស្មើនឹង ២៥

២-ប្រធាននាយកដ្ឋាន ប្រធានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី-ខេត្ត និងអនុប្រធាននាយកដ្ឋាន និងមុខតំណែងប្រហាក់ប្រហែល មានសន្ទស្សន៍ស្មើនឹង ៣០

៣-ប្រធានការិយាល័យថ្នាក់កណ្តាល អនុប្រធានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អនុប្រធានរតនាគាររាជធានី-ខេត្ត មានសន្ទស្សន៍ស្មើនឹង ៧៥

៤-អនុប្រធានការិយាល័យថ្នាក់កណ្តាល និង ប្រធានការិយាល័យនៃមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរតនាគាររាជធានី-ខេត្ត និងមុខតំណែងប្រហាក់ប្រហែល មានសន្ទស្សន៍ស្មើនឹង ៩០

៥-អនុប្រធានការិយាល័យមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង រតនាគាររាជធានី ខេត្ត មន្ត្រី មន្ត្រីជាប់កិច្ចសន្យា បុគ្គលិកជាប់កិច្ចសន្យា ទីប្រឹក្សា និងជំនួយការ មានសន្ទស្សន៍ស្មើនឹង ១០០។

**ខ- ប្រាក់ឧបត្ថម្ភមុខងារ** ត្រូវផ្តល់ប្រចាំខែ និងត្រូវបានកំណត់ជាសន្ទស្សន៍ ដូចខាងក្រោម៖

១-រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានសន្ទស្សន៍ស្មើនឹង ២១០៥

២-សន្ទស្សន៍ពិសេស មានសន្ទស្សន៍ស្មើនឹង ១៨៤២

៣-រដ្ឋលេខាធិការ នាយកខុទ្ទកាល័យ មានសន្ទស្សន៍ស្មើនឹង ១៣១៦

៤-ប្រធានទីប្រឹក្សា មានសន្ទស្សន៍ស្មើនឹង ១១៨៤

៥-អនុរដ្ឋលេខាធិការ មានសន្ទស្សន៍ស្មើនឹង ១០៥៣

៦-អនុប្រធានទីប្រឹក្សា មានសន្ទស្សន៍ស្មើនឹង ៩២១

៧-ទីប្រឹក្សាបច្ចេកទេសជាន់ខ្ពស់ មានសន្ទស្សន៍ស្មើនឹង ៧៩០

៨-ប្រធានគម្រោង និងមន្ត្រីខុទ្ទកាល័យ មានសន្ទស្សន៍ស្មើនឹង ៥២៦

៩-អនុប្រធានគម្រោង និងប្រធានក្រុមជំនួយការរដ្ឋលេខាធិការ មានសន្ទស្សន៍ស្មើនឹង ៣៩៥

១០-ប្រធានក្រុមការងារ អនុប្រធានក្រុមជំនួយការរដ្ឋលេខាធិការ ប្រធានក្រុមជំនួយការអនុរដ្ឋលេខាធិការ មានសន្ទស្សន៍ស្មើនឹង ៣៤២

១១-មន្ត្រីជំនាញជាន់ខ្ពស់ និង ទីប្រឹក្សាក្រសួង មានសន្ទស្សន៍ស្មើនឹង ២៦៣

១២-មន្ត្រីជំនាញ និងសមាជិកក្រុមជំនួយការ មានសន្ទស្សន៍ស្មើនឹង ២១១។

គម្រោងត្រូវមានទំហំការងារ ដែលត្រូវអនុវត្តក្នុងរយៈពេលចាប់ពីមួយឆ្នាំឡើងទៅ។ សម្រាប់ទំហំការងារ ដែលត្រូវអនុវត្តក្នុងរយៈពេលតិចជាងមួយឆ្នាំ ត្រូវបង្កើតត្រឹមតែកម្រិតនៃក្រុមការងារ។ សម្រាប់ទំហំការងារដែល ត្រូវអនុវត្តក្នុងរយៈពេលតិចជាង ៣ខែ ត្រូវអនុវត្តក្នុងក្របខណ្ឌការងារប្រចាំថ្ងៃធម្មតា។



k

ថ្នាក់ដឹកនាំ មន្ត្រីរាជការ ឬបុគ្គលិកម្នាក់ៗអាចចូលរួមអនុវត្តការងារក្នុងគម្រោង ឬក្រុមការងារលើសពីមួយបានគិតទាំងគម្រោងជាមួយដៃគូអភិវឌ្ឍ គម្រោងមូលនិធិផ្សេងៗ និងសមាជិកភាពនៃក្រុមប្រឹក្សាភិបាលនៃសហគ្រាសសាធារណៈ និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ប៉ុន្តែអនុញ្ញាតឱ្យទទួលប្រាក់ឧបត្ថម្ភមុខងារបានតែមួយប៉ុណ្ណោះ។

ក្នុងករណីមានជំនាញពិសេសចាំបាច់ ដែលជាក់ស្តែងតម្រូវឱ្យមានការផ្តល់ប្រាក់ឧបត្ថម្ភមុខងារខ្ពស់ គណៈកម្មាធិការវាយតម្លៃសមិទ្ធកម្ម និងផ្តល់ការលើកទឹកចិត្ត អាចពិនិត្យនិងសម្រេចលើសំណើផ្តល់តាមសន្ទស្សន៍ណាមួយក្នុងចំណោមសន្ទស្សន៍ដែលបានកំណត់ខាងលើ លើកលែងតែសន្ទស្សន៍រដ្ឋមន្ត្រី។

**គ- ប្រាក់រង្វាន់សមិទ្ធកម្ម** ត្រូវផ្តល់ប្រចាំត្រីមាស ឬឆមាស ឬឆ្នាំ ទៅតាមពេលវេលាជាក់ស្តែងដែលបានកំណត់សម្រាប់ការវាស់វែងសមិទ្ធកម្ម និងត្រូវបានកំណត់ដោយផ្អែកលើការសម្រេចលទ្ធផលការងារលើសគោលដៅដូចតទៅ៖

***១- ករណីចំណូល*** ដែលបានប្រមូលលើសគោលដៅកំណត់ រង្វាន់សមិទ្ធកម្មត្រូវផ្តល់ជូនជាភាគរយនៃប្រាក់ចំណូលដែលលើសដល់សាមីអង្គភាព ឬក្រុមការងារ ដែលបានអនុវត្តការប្រមូលចំណូលនោះផ្ទាល់។ ចំណូលដែលជាកម្មវត្ថុសម្រាប់ការផ្តល់រង្វាន់សមិទ្ធកម្ម គឺជាចំណូលសរុបរបស់អង្គភាពអនុវត្តផ្ទាល់នីមួយៗ ធៀបនឹងគោលដៅដែលបានកំណត់នៅក្នុងផ្ទៃក្នុងអគ្គនាយកដ្ឋាន គឺមិនមែនចំណូលសរុបរបស់អគ្គនាយកដ្ឋានធៀបនឹងច្បាប់ប្រចាំឆ្នាំ ឬ/និងប្រភេទចំណូលថ្មីដែលរាជរដ្ឋាភិបាលបានដាក់ចេញនោះទេ។ រង្វាន់សមិទ្ធកម្មនេះត្រូវផ្តល់ជូនប្រចាំឆ្នាំ និងត្រូវគិតជាភាគរយនៃប្រាក់ចំណូលលើសគោលដៅតាមអត្រាដូចខាងក្រោម៖

- ៥០ភាគរយ ក្នុងករណីចំណូលលើសមានចំនួនក្រោម ២០០ ០០០ ០០០ (ពីររយលាន) រៀល
- ៣០ភាគរយ ក្នុងករណីចំណូលលើសមានចំនួនចាប់ពី ២០០ ០០០ ០០០ (ពីររយលាន) រៀល រហូតដល់ក្រោម ៥០០ ០០០ ០០០ (ប្រាំរយលាន) រៀល
- ២០ភាគរយ ក្នុងករណីចំណូលលើសមានចំនួនចាប់ពី ៥០០ ០០០ ០០០ (ប្រាំរយលាន) រៀល រហូត ដល់ក្រោម ១ ០០០ ០០០ ០០០ (មួយពាន់លាន) រៀល
- ១៥ភាគរយ ក្នុងករណីចំណូលលើសមានចំនួនចាប់ពី ១ ០០០ ០០០ ០០០ (មួយពាន់លាន) រៀល រហូតដល់ក្រោម ២ ០០០ ០០០ ០០០ (ពីរពាន់លាន) រៀល
- ១០ភាគរយ ក្នុងករណីចំណូលលើសមានចំនួនចាប់ពី ២ ០០០ ០០០ ០០០ (ពីរពាន់លាន) រៀល រហូត ដល់ក្រោម ៤ ០០០ ០០០ ០០០ (បួនពាន់លាន) រៀល
- ៥ភាគរយ ក្នុងករណីចំណូលលើសមានចំនួនចាប់ពី ៤ ០០០ ០០០ ០០០ (បួនពាន់លាន) រៀល ឡើងទៅ។

***២- ករណីចំណាយ*** ដែលត្រូវបានអនុវត្តដោយភាពសន្សំសំចៃ និងនៅសល់ពីកម្រិតចំណាយដែលបានគ្រោង និងផ្តល់តាមគោលការណ៍កំណត់ដោយសម្រេចបានលទ្ធផលការងារតាមការរំពឹងទុករង្វាន់សមិទ្ធកម្មត្រូវផ្តល់ជូនក្នុងអត្រា ៥០% នៃចំនួនទឹកប្រាក់ដែលនៅសល់ ដល់សាមីអង្គភាព គម្រោង ឬ ក្រុមការងារ ដែលបានអនុវត្តការចំណាយនោះដោយផ្ទាល់។ ចំណាយដែលជាកម្មវត្ថុនៃការផ្តល់រង្វាន់សមិទ្ធកម្មគឺជាចំណាយតាមមុខសញ្ញានីមួយៗដែលបានគ្រោង និងផ្តល់តាមគោលការណ៍កំណត់ និងដែលមានសូចនាករ និងគោលដៅសម្រាប់វាស់លទ្ធផលច្បាស់លាស់ គឺមិនមែនចំណាយសរុបរបស់អង្គភាពនោះទេ។

***៣- ករណីផែនការការងារ*** ដែលត្រូវបានអនុវត្ត និងសម្រេចបានមុនកាលកំណត់ រង្វាន់សមិទ្ធកម្មត្រូវផ្តល់ជូនតាមអត្រានៃប្រាក់ឧបត្ថម្ភមុខងារសម្រាប់រយៈពេលដែលនៅសល់ដល់សាមីអង្គភាព គម្រោង ឬក្រុមការងារដែលបានសម្រេចផែនការការងារមុនកាលកំណត់ដោយផ្ទាល់។

**ឃ- មូលនិធិគាំទ្រស្ថាប័ន** ត្រូវផ្តល់ដល់អង្គភាពដោយផ្អែកលើផែនការអភិវឌ្ឍន៍ស្ថាប័នរបស់អង្គភាព និងតម្រូវការចាំបាច់ក្នុងការអនុវត្តកម្មវិធីគោលនយោបាយរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងអាស្រ័យលើលទ្ធភាពនៃមូលនិធិជាក់ស្តែងប្រចាំឆ្នាំ។

សន្ទស្សន៍ អាចត្រូវបានកែសម្រួលសមស្របតាមរយៈប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ការលើកទឹកចិត្តទាំង ៤ ប្រភេទខាងលើនេះ អាចទទួលត្រួតគ្នាបាន។

## ជំពូកទី៣
## យន្តការ នីតិវិធីនិងការត្រួតពិនិត្យ និងវាយតម្លៃ

**ប្រការ៧.-**

ថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលរួមមាន រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ រួមទាំងទីប្រឹក្សានិងជំនួយការក្រសួង ត្រូវទទួលបានការលើកទឹកចិត្តដោយផ្អែកលើសមិទ្ធកម្មការងារតាមការកំណត់និងវាយតម្លៃដោយផ្ទាល់របស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ប្រការ៨.-**

គោលការណ៍ យន្តការ វិធាន នីតិវិធី និងការត្រួតពិនិត្យចំពោះការផ្តល់ប្រាក់ឧបត្ថម្ភលើកទឹកចិត្តសម្រាប់អង្គភាពប្រតិបត្តិគម្រោង និងអង្គភាពអនុវត្តគម្រោងដែលប្រើប្រាស់រង្វាន់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវកំណត់ដោយសារាចររបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ប្រការ៩.-**

ត្រូវបង្កើតគណៈកម្មាធិការវាយតម្លៃសមិទ្ធកម្ម និងផ្តល់ការលើកទឹកចិត្តនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលសរសេរជាអក្សរកាត់ថា **គ.ស.ល** ដែលមានសមាសភាពដូចខាងក្រោម៖

| | |
|---|---|
| ១- រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ប្រធាន |
| ២- រដ្ឋលេខាធិការប្រចាំការក្រសួងសេដ្ឋកិច្ចនិងហិញ្ញវត្ថុ | អនុប្រធាន |
| ៣- រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ១ រូប | អនុប្រធានប្រចាំការ |
| ៤- អគ្គលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ៥- ប្រធាននាយកដ្ឋានបុគ្គលិក នៃអគ្គលេខាធិការដ្ឋានក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក។ |

សមាសភាពជាក់ស្តែងនៃ **គ.ស.ល** ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ក្នុងការបំពេញមុខងាររបស់ខ្លួន **គ.ស.ល** មានអគ្គលេខាធិការដ្ឋានក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាសេនាធិការបច្ចេកទេស ដោយមាននាយកដ្ឋានបុគ្គលិកជាលេខាធិការដ្ឋាន។

**ប្រការ១០.-**

**គ.ស.ល** មានមុខងារនិងភារកិច្ច ដូចខាងក្រោម៖

- ពិនិត្យនិងអនុម័តលើសេចក្តីព្រាងផែនការលើកទឹកចិត្ត និងផែនការអភិវឌ្ឍន៍ស្ថាប័នរបស់គ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ពិនិត្យនិងសម្រេចលើការផ្តល់ការលើកទឹកចិត្ត ផ្អែកលើផែនការលើកទឹកចិត្ត និងផែនការអភិវឌ្ឍន៍ស្ថាប័ន ដែលបានអនុម័ត
- ពិនិត្យនិងសម្រេចលើវឌ្ឍនភាពនៃការអនុវត្តផែនការលើកទឹកចិត្ត និងផែនការអភិវឌ្ឍន៍ស្ថាប័នរបស់ គ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ពិនិត្យតាមដានលើប្រតិបត្តិការចំណាយដែលមានលក្ខណៈជាការទិញ ជួល សេវាកម្ម និងចំណាយមូលធនផ្សេងៗដែលប្រើប្រាស់ថវិការង្វាន់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ប្រការ១១.-**

**គ.ស.ល** ត្រូវកោះប្រជុំតាមការចាំបាច់។ ប្រធាន **គ.ស.ល** អាចប្រគល់សិទ្ធិជូនអនុប្រធានដឹកនាំកិច្ចប្រជុំជំនួស និងអាចអញ្ជើញថ្នាក់ដឹកនាំក្រសួង និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន និងអគ្គាធិការដ្ឋានឱ្យចូលរួមកិច្ចប្រជុំតាមការចាំបាច់។ សមាសភាព **គ.ស.ល** មានសិទ្ធិអញ្ជើញប្រធាន អនុប្រធាន និងសមាជិកក្រុមការងារវាយតម្លៃសមិទ្ធកម្ម និងផ្តល់ការលើកទឹកចិត្ត ប្រជុំតាមតម្រូវការចាំបាច់។



4

**ប្រការ១២.-**

**គ.ស.ល** មានក្រុមការងារវាយតម្លៃសមិទ្ធកម្ម និងផ្តល់ការលើកទឹកចិត្ត (ក.ស.ល) ជាសេនាធិការក្នុងកិច្ចដំណើរការបច្ចេកទេស និងរៀបចំបូកសរុបរបាយការណ៍ជូនថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយមានសមាសភាពដូចខាងក្រោម៖

| | |
|---|---|
| ១- អគ្គលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ប្រធាន |
| ២- ប្រធាននាយកដ្ឋានបុគ្គលិក នៃអគ្គលេខាធិការដ្ឋាន កសហវ. | អនុប្រធាន និងជាប្រធានលេខាធិការដ្ឋាន |
| ៣- អនុប្រធាននាយកដ្ឋានបុគ្គលិក ១ រូប | អនុប្រធានលេខាធិការដ្ឋាន |

៤- មន្ត្រី មួយចំនួននៃនាយកដ្ឋានបុគ្គលិក នៃអគ្គលេខាធិការដ្ឋាន កសហវ. សមាជិក។

**ប្រការ១៣.-**

**គ.ស.ល** មានមុខងារនិងភារកិច្ច ដូចខាងក្រោម៖

- ពិនិត្យ រៀបចំ បូកសរុបលើផែនការលើកទឹកចិត្ត និងផែនការអភិវឌ្ឍន៍ស្ថាប័នរបស់គ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ពិនិត្យនិងផ្តល់យោបល់លើសេចក្តីព្រាងផែនការលើកទឹកចិត្ត និងផែនការអភិវឌ្ឍន៍ស្ថាប័នរបស់គ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដាក់ជូន **គ.ស.ល** ពិនិត្យសម្រេច
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើវឌ្ឍនភាពនៃការអនុវត្តផែនការលើកទឹកចិត្ត និងផែនការអភិវឌ្ឍន៍ស្ថាប័ននៃគ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- តាមដាន ត្រួតពិនិត្យ និងផ្តល់យោបល់លើការស្នើសុំនិងការប្រើប្រាស់រង្វាន់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បំពេញការងារផ្សេងទៀតតាមការប្រគល់ជូនរបស់ **គ.ស.ល** ។

**ប្រការ១៤.-**

ត្រូវបង្កើតគណៈកម្មាធិការវាយតម្លៃសមិទ្ធកម្ម និងផ្តល់ការលើកទឹកចិត្ត នៅតាមអង្គភាព ដែលមានសមាសភាពដូចខាងក្រោម៖

| | |
|---|---|
| ១- អគ្គលេខាធិការ/អគ្គនាយក/អគ្គាធិការ | ប្រធាន |
| ២- អគ្គលេខាធិការរង/អគ្គនាយករង/អគ្គាធិការរង ០១ ឬច្រើនរូប | អនុប្រធាន |
| ៣- ប្រធាននាយកដ្ឋាន ឬ/និងប្រធានលេខាធិការដ្ឋាន | សមាជិក |
| ៤- អនុប្រធាននាយកដ្ឋាន ឬ/និងប្រធានការិយាល័យ | សមាជិក។ |

សមាសភាពជាក់ស្តែងនៃគណៈកម្មាធិការវាយតម្លៃសមិទ្ធកម្ម និងផ្តល់ការលើកទឹកចិត្តនៅតាមអង្គភាព ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

គណៈកម្មាធិការនេះត្រូវមានលេខាធិការដ្ឋាន ឬអង្គភាពប្រហាក់ប្រហែលជាសេនាធិការក្នុងការបំពេញមុខងាររបស់ខ្លួន។

**ប្រការ១៥.-**

គណៈកម្មាធិការវាយតម្លៃសមិទ្ធកម្ម និងផ្តល់ការលើកទឹកចិត្ត នៅតាមអង្គភាពមានមុខងារនិងភារកិច្ចដូចខាងក្រោម៖

- រៀបចំសេចក្តីព្រាងផែនការលើកទឹកចិត្ត ដើម្បីដាក់ជូន **គ.ស.ល** ពិនិត្យ និងអនុម័ត
- ពិនិត្យសម្រេច និងអនុវត្តផែនការផ្តល់ការលើកទឹកចិត្តនៃអង្គភាពរបស់ខ្លួន
- ត្រួតពិនិត្យនិងវាយតម្លៃលើវឌ្ឍនភាពនៃការអនុវត្តផែនការលើកទឹកចិត្តនៃអង្គភាពរបស់ខ្លួន។

អង្គភាពប្រើប្រាស់រង្វាន់ក្រសួង អាចបង្កើតក្រុមការងារវាយតម្លៃសមិទ្ធកម្ម និងផ្តល់ការលើកទឹកចិត្តនៅតាមនាយកដ្ឋាន និងអង្គភាពក្រោមឱវាទក្នុងករណីចាំបាច់។

**ប្រការ១៦.-**

គណៈកម្មាធិការវាយតម្លៃសមិទ្ធកម្ម និងផ្ដល់ការលើកទឹកចិត្តនៅតាមអង្គភាព ត្រូវកោះប្រជុំ ត្រីមាស និងប្រចាំឆ្នាំ ឬតាមការចាំបាច់។ ប្រធានគណៈកម្មាធិការវាយតម្លៃសមិទ្ធកម្មនិងផ្ដល់ការលើកទឹកចិត្តនៅតាមអង្គភាព អាចប្រគល់សិទ្ធិជូនអនុប្រធានដឹកនាំកិច្ចប្រជុំជំនួស និងអាចអញ្ជើញប្រធានគម្រោង ឬ/និងប្រធានក្រុមការងារផ្សេងៗ ឱ្យចូលរួមកិច្ចប្រជុំតាមការចាំបាច់។

**ប្រការ១៧.-**

អង្គភាព ត្រូវរៀបចំផែនការលើកទឹកចិត្ត ប្រចាំឆ្នាំ ដែលត្រូវមាន៖

- ផែនការសកម្មភាពសម្រាប់ផ្ដល់ការលើកទឹកចិត្តរបស់អង្គភាពសាមីក្នុងការអនុវត្តកម្មវិធី និងគោលនយោបាយរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- គម្រោងថវិកាសម្រាប់អនុវត្តផែនការផ្ដល់ការលើកទឹកចិត្ត ដែលត្រូវកំណត់ទៅតាមប្រភេទនៃការលើកទឹកចិត្តនីមួយៗ
- បញ្ជីឈ្មោះមន្ត្រីដែលត្រូវទទួលប្រាក់ឧបត្ថម្ភ ឬ/និងប្រាក់រង្វាន់នៅតាមគម្រោង ឬ/និងក្រុមការងារ។

**ប្រការ១៨.-**

គណៈកម្មាធិការវាយតម្លៃសមិទ្ធកម្មនិងផ្ដល់ការលើកទឹកចិត្តរបស់អង្គភាព ត្រូវផ្ដល់ផែនការលើកទឹកចិត្តប្រចាំឆ្នាំរបស់ខ្លួនមក **គ.ស.ល** ត្រឹមដំណាច់ខែតុលាមុនឆ្នាំអនុវត្ត ដើម្បី **គ.ស.ល** ពិនិត្យបូកសរុបជូន **គ.ស.ល** ពិនិត្យសម្រេចលើផែនការលើកទឹកចិត្តរបស់ក្រសួង ត្រឹមដំណាច់ខែមករានៃឆ្នាំអនុវត្ត។

ផែនការលើកទឹកចិត្ត ដែលត្រូវបានអនុម័តដោយ **គ.ស.ល** ត្រូវបញ្ជូនទៅសាមីអង្គភាពដើម្បីអនុវត្ត។

ផែនការលើកទឹកចិត្ត ត្រូវទទួលការត្រួតពិនិត្យនិងវាយតម្លៃវឌ្ឍនភាពប្រចាំត្រីមាស ប្រចាំឆ្នាំ និងនៅរៀងរាល់ពេលបញ្ចប់គម្រោង ឬក្រុមការងារ ដោយគណៈកម្មាធិការវាយតម្លៃសមិទ្ធកម្មនិងផ្ដល់ការលើកទឹកចិត្តនៅតាមអង្គភាព ហើយត្រូវធ្វើរបាយការណ៍ តាមប្រភេទនីមួយៗ ជូន **គ.ស.ល** ជាទៀងទាត់ ទៅតាមគណៈប្រតិទិននីមួយៗ។

គណៈកម្មាធិការវាយតម្លៃសមិទ្ធកម្មនិងផ្ដល់ការលើកទឹកចិត្ត នៅតាមអង្គភាព មានសិទ្ធិលុបឈ្មោះមន្ត្រីចេញពីបញ្ជីទទួលការលើកទឹកចិត្ត និងផ្លាស់ប្ដូរមន្ត្រីបម្រើការងារតាមគម្រោង ឬក្រុមការងារនៅក្នុងឆ្នាំបានតាមរយៈការរៀបចំលិខិតសំណើមកកាន់ **គ.ស.ល** ។

**ប្រការ១៩.-**

អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង ត្រូវត្រួតពិនិត្យអំពីសមិទ្ធកម្មនៃផែនការលើកទឹកចិត្តរបស់ **គ.ស.ល** ហើយរាយការណ៍ ជូន **គ.ស.ល** ពិនិត្យនិងចាត់វិធានការក្នុងករណីចាំបាច់។

## ជំពូកទី៤
## អន្តរប្បញ្ញត្តិ

**ប្រការ២០.-**

អង្គភាពក្រោមឱវាទ និងក្រោមអាណាព្យាបាលក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងអង្គភាពក្រោមអាណាព្យាបាលរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវចាប់ផ្ដើមអនុវត្តតាមគោលការណ៍ នីតិវិធី យន្តការនិងការត្រួតពិនិត្យការផ្ដល់ការលើកទឹកចិត្តដែលមានចែង នៅក្នុងប្រកាសនេះចាប់ពីថ្ងៃទី០១ ខែតុលា ឆ្នាំ២០២៤។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានសិទ្ធិសម្រេចក្នុងការអនុញ្ញាតឱ្យអង្គភាព ប្រើប្រាស់យន្តការលើកទឹកចិត្តដោយឡែក។

តម្លៃឯកតានៃសន្ទស្សន៍ត្រូវបានកំណត់ស្មើនឹង ៣ ៨០០ (បីពាន់ប្រាំបីរយ) រៀល។ តម្លៃឯកតានៃសន្ទស្សន៍នេះអាចធ្វើការកែសម្រួលបានតាមការចាំបាច់ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី៥
## អវសានប្បញ្ញត្តិ

**ប្រការ២១.-**

ប្រកាសលេខ ៦១៦ សហវ.ប្រក ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៤ ស្តីពីការកំណត់គោលការណ៍ យន្តការ នីតិវិធី និងការត្រួតពិនិត្យ សម្រាប់ការផ្តល់ការលើកទឹកចិត្តដោយប្រើប្រាស់ប្រាក់រង្វាន់របស់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រកាស ២៦៥ សហវ.ប្រក ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលប្រការ៦ នៃប្រកាសលេខ ៦១៦ សហវ.ប្រក ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៤ ស្តីពីការកំណត់គោលការណ៍ យន្តការ នីតិវិធី និងការត្រួតពិនិត្យ សម្រាប់ការផ្តល់ការលើកទឹកចិត្តដោយប្រើប្រាស់ប្រាក់រង្វាន់ របស់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ២២.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយក អគ្គាធិការ ថ្នាក់ដឹកនាំគ្រប់អង្គភាពក្រោមឱវាទ និងក្រោមអាណាព្យាបាលក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងគ្រប់អង្គភាពក្រោមអាណាព្យាបាលរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលប្រើប្រាស់រង្វាន់ក្រសួង ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ខែ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ឆ្នាំ២០២៤

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

អគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**

- គ្រប់ថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ដូចប្រការ ២២
- ឯកសារ-កាលប្បវត្តិ